# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center

*“កាន់តែមានការជជែកដេញដោលជាសាធារណៈ កាន់តែធ្វើឲ្យ... ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី និងសាធារណជន នឹងបានយល់ដឹងអំពីអ្វីដែលបានកើតឡើង និង អ្វីដែលជាការពិត”*

***អេលីហ្សាប៉ែត ស៊ីម៉ូណូ ហ្វត***

*សហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី*

## I- **និដ្ឋភាពទូទៅ**

នៅថ្ងៃទី២៩ ដល់ ៣១ ខែសីហា ឆ្នាំ២០១១ អង្គជំនុំជម្រះបានបើកសវនាការដំបូង ស្តីពីបញ្ហាកាយសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ លើករណីលោកស្រី **អៀង ធីរិទ្ធ** និងលោក **នួន ជា** ក្រោយពីការដាក់របាយការណ៍ដោយអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ សាស្ត្រាចារ្យ **ចន ខេមប៊ែល**[i] ដែលអង្គជំនុំជម្រះបានតែងតាំងឲ្យធ្វើកោសលវិច័យលើសុខភាពជនជាប់ចោទបីរូប រួមមាន លោក **អៀង សារី** លោកស្រី **អៀង ធីរិទ្ធ** និងលោក **នួន ជា**[ii]។

បញ្ហាពាក់ព័ន្ធនឹងគុណសម្បត្តិរបស់អ្នកជំនាញ **ចន ខេមប៊ែល** និងអំពីវិធីសាស្ត្រដែលគាត់បានប្រើប្រាស់សម្រាប់ធ្វើកោសលវិច័យត្រូវបានលើកយកមកពិភាក្សារួមនៅថ្ងៃដំបូង។ ការពិភាក្សាអំពីបញ្ហាវិធីសាស្ត្រ លោកសាស្ត្រាចារ្យបានពន្យល់អំពីប្រភពនានាដែលគាត់បានយកមកធ្វើការវាយតម្លៃ។ ថ្ងៃទីពីរ គឺផ្តោតសំខាន់ទៅលើរបាយការណ៍របស់សាស្ត្រាចារ្យ **ចន ខេមប៊ែល** ដែលបានឲ្យដឹងថា ជនជាប់ចោទ **អៀង ធីរិទ្ធ** ទំនងជាមានជម្ងឺបាត់បង់ស្មារតី (Alzheimer) ដែលអាចជាជំងឺវិកលចរិត (dementia)។ សាស្ត្រាចារ្យ **ចន ខេមប៊ែល** បានរកឃើញថា ការយល់ដឹងរបស់ជនជាប់ចោទ **អៀង ធីរិទ្ធ** មានភាពចុះខ្សោយដល់កម្រិតមួយ ដែលពុំអាចឲ្យគាត់មានលទ្ធភាពក្នុងការចូលរួមសវនាការដោយពេញលេញ

នោះទេ។ នាថ្ងៃចុងក្រោយ លោកវេជ្ជបណ្ឌិតបានបញ្ជាក់ថា ផ្អែកតាមការវាយតម្លៃរបស់គាត់ លោក **នួន ជា** មានកាយសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ។

## II. បញ្ហាផ្លូវច្បាប់ និងបញ្ហានីតិវិធី

បញ្ហាដែលលើកយកមកពិភាក្សាក្នុងអំឡុងពេលសវនាការ បីថ្ងៃនេះ រួមមាន៖ (ក) គុណសម្បត្តិរបស់សាស្ត្រាចារ្យ **ចន ខេមប៊េល** (ខ) វិធីសាស្ត្រដែលគាត់បានប្រើប្រាស់ក្នុងការធ្វើកោសលវិច័យទៅលើសុខភាពរបស់លោកស្រី **អៀង ធីរិទ្ធ** និងលោក **នួន ជា** (គ) សេចក្តីសន្និដ្ឋានរបស់សាស្ត្រាចារ្យ **ចន ខេមប៊េល** អំពីសុខភាពផ្លូវចិត្តរបស់ជនជាប់ចោទ **អៀង ធីរិទ្ធ** (ឃ) សេចក្តីសន្និដ្ឋានរបស់សាស្ត្រាចារ្យ **ចន ខេមប៊េល** អំពីសុខភាពផ្លូវចិត្តរបស់លោក **នួន ជា** (ង) សិទ្ធិរបស់ជនជាប់ចោទក្នុងការផ្តល់ព័ត៌មានលម្អិតអំពីបញ្ហាសុខភាពរបស់ខ្លួនជាសម្ងាត់ ផ្ទុយទៅវិញ សិទ្ធិរបស់សាធារណជនក្នុងការទទួលបានព័ត៌មាន និង (ច) សិទ្ធិរបស់ជនជាប់ចោទក្នុងការមិនបង្ហាញខ្លួនក្នុងបន្ទប់សវនាការ។

### ក. គុណសម្បត្តិរបស់សាស្ត្រាចារ្យ ចន ខេមប៊េល

នៅពេលចាប់ផ្តើមសវនាការនាថ្ងៃទីមួយ ភាគីបានចោទសួរសាស្ត្រាចារ្យ **ចន ខេមប៊េល** អំពីគុណសម្បត្តិរបស់លោក។ លោកសាស្ត្រាចារ្យបានផ្តល់សក្ខីកម្មថា គាត់ជាអ្នកជំនាញម្នាក់មកពីប្រទេស **នូវែលសេឡង់** (ញ៉ូហ្សេលែន) ដែលមានបទពិសោធន៍ផ្នែកព្យាបាល និងផ្នែកសិក្សាស្រាវជ្រាវវេជ្ជសាស្ត្រព្យាបាលជំងឺមនុស្សចាស់។ គាត់បាននិពន្ធ និងធ្លាប់ជាសហនិពន្ធសៀវភៅជាច្រើនពាក់ព័ន្ធនឹងបញ្ហានេះ (ជាងមួយរយច្បាប់) និងត្រូវបានបោះពុម្ពផ្សាយជាសាធារណៈ។ នាពេលបច្ចុប្បន្ននេះ លោកសាស្ត្រាចារ្យបានធ្វើការងារជាទីប្រឹក្សានៅមន្ទីរព្យាបាលរោគ ជាគ្រូបង្រៀន និងជាអ្នកស្រាវជ្រាវផ្នែកវេជ្ជសាស្ត្រព្យាបាលជំងឺមនុស្សចាស់។

ក្នុងអំឡុងពេលសវនាការ ចៅក្រម ព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តីរបស់លោកស្រី **អៀង ធីរិទ្ធ** បានទទួលស្គាល់ពីគុណសម្បត្តិរបស់សាស្ត្រាចារ្យ **ចន ខេមប៊េល** ថាជាអ្នកជំនាញ។ ដើម្បីគាំទ្រនូវទឡ្ហីករណ៍របស់ខ្លួន លោកស្រី **ដាយអេណា អ៊ែលីស** ជាមេធាវីការពារក្តីអន្តរជាតិរបស់លោកស្រី **អៀង ធីរិទ្ធ** បានគូសបញ្ជាក់អំពីបទពិសោធន៍ជាច្រើនរបស់សាស្ត្រាចារ្យ **ចន ខេមប៊េល** នៅក្នុងផ្នែកជំនាញថែទាំព្យាបាលជំងឺមនុស្សចាស់ ក៏ដូចជាតួនាទីដែលមានកិត្តិនាមជាច្រើនទៀត។

ចំណែកឯក្រុមមេធាវីការពារក្តីរបស់លោក **នួន ជា** តាមរយៈមេធាវី **ចាស្ទី ផាវ** បានថ្លែងបដិសេធម្តងហើយម្តងទៀតពីភាពជឿជាក់លើអ្នកជំនាញ **ចន ខេមប៊េល** ដោយមិនពេញចិត្តនឹងលទ្ធផលកោសលវិច័យលើកូនក្តីរបស់គាត់។ មេធាវី **ចាស្ទី ផាវ** បានរិះរកនូវមន្ទិលសង្ស័យនានាអំពីភាពមិនជឿទុកចិត្តនៃរបាយការណ៍របស់សាស្ត្រាចារ្យ **ចន ខេមប៊េល** ។ មេធាវី **ចាស្ទី ផាវ** បានគូសបញ្ជាក់អំពីភាពកង្វះពិសោធន៍របស់លោកសាក្សីជំនាញក្នុងការធ្វើកោសលវិច័យលើបញ្ហាកាយសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ។

នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល សហព្រះរាជអាជ្ញាអន្តរជាតិលោក **ថារីក អាប់ឌុលហាក់**

បានជំទាស់នឹងទឡ្ហីករណ៍របស់មេធាវីលោក **នួន ជា** ដោយបានកត់សម្គាល់ថា ក្រុមមេធាវីការពារក្តីលោក **នួន ជា** មិនបានដាក់ការជំទាស់ណាមួយ និងមិនបានប្រឆាំងនឹងគុណសម្បត្តិរបស់សាស្ត្រាចារ្យ **ចន ខេមប៊ែល** ចាប់តាំងពីពេលអង្គជំនុំជម្រះសាលាដំបូងតែងតាំងសាក្សីជំនាញរូបនេះ ឬសូម្បីតែបន្ទាប់ពីពេលដែលសាស្ត្រាចារ្យ **ចន ខេមប៊ែល** បានដាក់របាយការណ៍របស់គាត់ ដែលនេះសបញ្ជាក់ច្បាស់ណាស់ថា ក្រុមមេធាវីការពារក្តីលោក **នួន ជា** បានទទួលស្គាល់ពីគុណសម្បត្តិរបស់សាស្ត្រាចារ្យ **ចន ខេមប៊ែល** ថាជាអ្នកជំនាញ។

**ខ. វិធីសាស្ត្រប្រើប្រាស់ក្នុងការវាយតម្លៃទៅលើសុខភាពរបស់ លោកស្រី អៀង ធីរិទ្ធ និង លោក នួន ជា**

ការសួរដេញដោលអំពីប្រធានបទវិធីសាស្ត្រ និងការធ្វើតេស្តសាកល្បង ដែលសាស្ត្រាចារ្យ **ចន ខេមប៊ែល** បានប្រើប្រាស់ក្នុងការវាយតម្លៃវេជ្ជសាស្ត្រទៅលើលោកស្រី **អៀង ធីរិទ្ធ** និងលោក **នួន ជា** គឺជាចំណោទចម្បងមួយនាសវនាការបីថ្ងៃនេះ។

សក្ខីកម្មរបស់សាស្ត្រាចារ្យ **ចន ខេមប៊ែល** បានពន្យល់ឲ្យដឹងអំពីប្រភពផ្សេងៗដែលគាត់បានប្រើជាមូលដ្ឋានសម្រាប់វាយតម្លៃលក្ខខណ្ឌសុខភាពរបស់ជនជាប់ចោទទាំងពីររូបនេះ។ គាត់បានបញ្ជាក់ថា មូលដ្ឋានចម្បងសម្រាប់ការវាយតម្លៃ គឺសិក្សាពីប្រវត្តិជម្ងឺរបស់ជនចោទចោទទាំងពីររូប ការសម្ភាសន៍ និងការពិនិត្យដោយផ្ទាល់។ ដើម្បីវាយតម្លៃប្រវត្តិជម្ងឺរបស់លោកស្រី **អៀង ធីរិទ្ធ** និងលោក **នួន ជា** សាស្ត្រាចារ្យ **ចន ខេមប៊ែល** បានប្រើវិធីសាស្ត្រដូចតទៅ ៖ (១) របាយការណ៍ចុះកាលបរិច្ឆេទឆ្នាំ២០០៩ ដោយអ្នកវិជ្ជាជីវៈដែលធ្លាប់ពិនិត្យលោកស្រី **អៀង ធីរិទ្ធ** គឺលោកវេជ្ជបណ្ឌិត **ប្រ៊ីនឌីត** និងសាស្ត្រាចារ្យ **កា** (២) របាយការណ៍វេជ្ជសាស្ត្រពីមន្ទីរពេទ្យកាល់ម៉ែត និងពីទីក្រុងបាងកក (៣) របាយការណ៍ពីវេជ្ជបណ្ឌិតរបស់សាលាក្តី និងបុគ្គលិកមន្ទីរឃុំឃាំង (៥) របាយការណ៍ពីបុគ្គលដែលបានថែទាំជនជាប់ចោទរៀងរាល់ថ្ងៃ និង (៦) បទសម្ភាសន៍ផ្ទាល់ជាមួយជនជាប់ចោទ។

បន្ថែមលើនេះ សាស្ត្រាចារ្យ **ចន ខេមប៊ែល** បានធ្វើតេស្តសាកល្បងចំនួនពីរលើក ក្នុងការវាយតម្លៃអំពីដំណើរការយល់ដឹងរបស់ជនជាប់ចោទទាំងពីររូប ៖ (១) ការពិនិត្យលក្ខណៈចិត្តសាស្ត្រអំពីការបាត់បង់ការចងចាំ បែប Folstein និង (២) ការវាយតម្លៃការចងចាំបែប Montreal។ សាស្ត្រាចារ្យ **ចន ខេមប៊ែល** បានពន្យល់ឲ្យដឹងថា ការធ្វើតេស្ត គឺជាឧបករណ៍វាយតម្លៃបន្ទាប់បន្សំមួយ ដោយគាត់យល់ឃើញពីភាពខុសគ្នានៃភាសា វប្បធម៌ និងភាពទូទៅនៃតេស្តសាកល្បងដែលធ្វើទៅលើបុគ្គល “បង្ហាញថា ពួកគាត់នៅតែមានសភាពធម្មតា ឬមានសភាពប្រក្រតីដូចដែលពួកគាត់ធ្លាប់មានពីមុន”[iii]

នៅពេលធ្វើតេស្តនេះ លោកសាស្ត្រាចារ្យបានសាកសួរលោកស្រី **អៀង ធីរិទ្ធ** អំពីប្រវត្តិផ្ទាល់ខ្លួនរបស់គាត់ ដើម្បីចង់ដឹងអំពីការចងចាំរបស់គាត់។ លោកសាស្ត្រាចារ្យបានឲ្យគាត់គូរមុខនាឡិកា និងចង្អុលទ្រនិចពេលវេលាឲ្យបានជាក់លាក់ គឺសាកល្បងអំពីសមត្ថភាពក្នុងការរៀបចំរបស់គាត់ (spatial orgazinign abilities)។ បន្ទាប់មក លោកសាស្ត្រាចារ្យ បានធ្វើតេស្តតាមដានជាបន្តបន្ទាប់ ដើម្បីយល់ដឹងអំពីសមត្ថភាពក្នុងការរៀបចំតាមលំដាប់លំដោយ (sequencing skill)។ លោកស្រី **អៀង ធីរិទ្ធ** ពុំបានជាប់នូវការសាកល្បងនេះទេ គឺគាត់ពុំមានការយល់ដឹងឡើយ។ លោកស្រី **អៀង ធីរិទ្ធ** មិនអាចនឹកឃើញប្រវត្តិផ្ទាល់ខ្លួនរបស់គាត់ តួយ៉ាង គាត់ភ័ន្តច្រឡំថ្ងៃកំណើតជាមួយនឹងថ្ងៃរៀបអាពាហ៍ពិពាហ៍របស់គាត់។

គាត់មិនទាំងចងចាំថា មានកូនប៉ុន្មាននាក់ និងមិនអាចកំណត់ម៉ោងនៅក្នុងនាឡិកាដែលបានគូរផង។ លើសពីនេះទៀត គាត់មិនអាចអនុវត្តតាមវិធីបន្តបន្ទាប់ដែលមាននៅក្នុងតេស្តទេ (trial-following test) ។ នៅពេលដែលអង្គជំនុំជម្រះ និងភាគីដទៃបានលើកឡើងពីក្តីបារម្ភដែលថា លោកស្រី **អៀង ធីរិទ្ធ** អាចមានចេតនាបំភ័ន្តលោកសាស្ត្រាចារ្យឲ្យមានការយល់ច្រឡំថា គាត់មានការបាត់បង់សតិស្មារតី សាស្ត្រាចារ្យ **ចន ខេមប៊េល** បានពន្យល់ដោយភាពជឿជាក់ថា តាមរយៈបទពិសោធន៍ជាច្រើនរបស់គាត់ក្នុងការធ្វើតេស្តសតិស្មារតី គាត់យល់ដឹងយ៉ាងច្បាស់នូវការធ្វើពុត ឬចេតនាបញ្ឆោតនានាជាក់ជាមិនខាន។ គាត់បានបញ្ជាក់ដោយមានជំនឿចិត្តទៀតថា លោកស្រី **អៀង ធីរិទ្ធ** មិនមានសមត្ថភាពក្នុងការធ្វើឲ្យគាត់យល់ខុសនោះទេ។

មេធាវីការពារក្តីរបស់លោក **នួន ជា** បានបដិសេធនឹងវិធីសាស្ត្ររបស់សាស្ត្រាចារ្យ **ចន ខេមប៊េល** និងការធ្វើតេស្តនានា ដែលសាក្សីជំនាញរូបនេះបានប្រើក្នុងការវាយតម្លៃសុខភាពកូនក្តីរបស់ខ្លួន។ មេធាវីបានលើកសំអាងថា ប្រភពដែលសាស្ត្រាចារ្យ **ចន ខេមប៊េល** បានប្រើក្នុងការវាយតម្លៃលើរូបលោក **នួន ជា** គឺមិនគ្រប់គ្រាន់ និងហាក់ដូចចាស់គំរិលពេកហើយ។ សាស្ត្រាចារ្យ **ចន ខេមប៊េល** បានជំទាស់វិញថា ប្រភពដែលគាត់បានប្រើប្រាស់ក្នុងការធ្វើរបាយការណ៍របស់គាត់ គឺមានប្រសិទ្ធភាពខ្ពស់ និងសមស្របតាមកាលវេលា ហើយគាត់អាចប្រមូលព័ត៌មានបន្ថែមប្រសិនបើចាំបាច់ ប៉ុន្តែវាមិនចាំបាច់នោះទេ។ លោក **ស៊ុន អារុណ** ដែលជាមេធាវីជាតិការពារក្តីឲ្យជនជាប់ចោទ **នួន ជា** បានអះអាងថា សាស្ត្រាចារ្យ **ចន ខេមប៊េល** មិនបានតាមដានឲ្យបានដិតដល់អំពីបញ្ហា ដូចជា ជម្ងឺដាច់សសៃឈាមខួរក្បាល និងជម្ងឺលើសឈាមដែលអាចប៉ះពាល់ដល់សមត្ថភាពផ្លូវចិត្តរបស់គាត់។ សាស្ត្រាចារ្យ **ចន ខេមប៊េល** បានពន្យល់តបវិញថា វាជាការធម្មតាទេចំពោះអ្នកមានជម្ងឺដាច់សសៃឈាមខួរក្បាលកម្រិតទាប អាចមានសម្ពាធឈាមខ្ពស់ ប៉ុន្តែវាមិនជះឥទ្ធិពលដល់មុខងារសតិស្មារតីនោះទេ។ មេធាវីការពារក្តីបានសង្កត់ធ្ងន់ថា សាស្ត្រាចារ្យ **ចន ខេមប៊េល** មិនបានចំណាយពេលវេលាគ្រប់គ្រាន់ក្នុងការសម្ភាសន៍ និងវាយតម្លៃលក្ខខណ្ឌសុខភាពរបស់លោក **នួន ជា** នោះទេ។ សាស្ត្រាចារ្យ **ចន ខេមប៊េល** បានបដិសេធការអះអាងនេះ ដោយបានបញ្ជាក់ថា ពេលវេលាដែលគាត់បានចំណាយជាមួយជនជាប់ចោទ គឺគ្រប់គ្រាន់ក្នុងការទទួលបានព័ត៌មានដែលគាត់ត្រូវការសម្រាប់ធ្វើកោសលវិច័យផ្នែកចិត្តសាស្ត្រ។

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានចង្អុលបង្ហាញថា មានភាពកង្វះខាតនូវឯកសារយោង ពាក់ព័ន្ធនឹងស្តង់ដារដែលបានកំណត់នៅក្នុងករណីរលោក **ផារលីស្ទ្រូហ្កា**[iv] ទាក់ទងនឹងសមត្ថភាពរបស់ជនជាប់ចោទក្នុងការចូលរួមដំណើរការនីតិវិធី។ ទោះជាយ៉ាងណាក៏ដោយ សាស្ត្រាចារ្យ **ចន ខេមប៊េល** បានបញ្ជាក់ថា គាត់ពិតជាបានពិចារណាទៅលើស្តង់ដារដែលបានកំណត់ក្នុងករណីលោក **ស្ទ្រូហ្កា** ក្នុងការកំណត់ការវាយតម្លៃរបស់គាត់។ លោកប្រធានអង្គជំនុំជម្រះបានបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូង និងអ្នកជំនាញវេជ្ជសាស្ត្រ ពុំមានសមត្ថកិច្ចក្នុងការសម្រេចដោយផ្អែកលើស្តង់ដារច្បាប់ដែលបានបញ្ជាក់ក្នុងករណីលោក **ស្ទ្រូហ្កា** នោះទេ។ អ្នកជំនាញគ្រាន់តែទទួលខុសត្រូវក្នុងការផ្តល់ព័ត៌មានវេជ្ជសាស្ត្រ និងព័ត៌មានបច្ចេកទេស ដែលនឹងជួយដល់អង្គជំនុំជម្រះក្នុងការសម្រេចចិត្តអំពីបញ្ហាកាយសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ។ ហេតុនេះ សាស្ត្រាចារ្យ **ចន ខេមប៊េល** មិនចាំបាច់លើកឡើងអំពីស្តង់ដារដែលបានកំណត់ក្នុងករណីលោក **ស្ទ្រូហ្កា** នៅក្នុងរបាយការណ៍វេជ្ជសាស្ត្ររបស់លោកឡើយ។

## គ. ការរកឃើញស្តីពីបញ្ហាកាយសម្បទារបស់លោក នួន ជា ក្នុងការចូលរួមសវនាការ

សាស្ត្រាចារ្យ **ចន ខេមប៊ើល** បានសង្ខេបការរកឃើញរបស់គាត់ទាក់ទងនឹងលក្ខខណ្ឌសុខភាពរបស់ជនជាប់ចោទ **នួន ជា** ថា៖ **ទីមួយ** ប្រព័ន្ធសរសៃឈាមក្នុងបេះដូងរបស់លោក **នួន ជា** មានសភាពធម្មតា ដោយហេតុថា គាត់មិនបានទទួលរងការដាច់សរសៃឈាមក្នុងខួរក្បាលទេ។ លោកសាស្ត្រាចារ្យបានឱ្យដឹងថា ការអង្គុយនៅក្នុងតុលាការនឹងមិនបង្កហានិភ័យដល់ការគាំងបេះដូង ឬដង្ហក់ផ្លូវដង្ហើមនោះឡើយ។ **ទីពីរ** មិនមានការរកឃើញថា ជម្ងឺសរសៃឈាមខួរក្បាល (cerebrovascular) បានប៉ះពាល់ដល់មុខងារភាសា ឬសតិស្មារតីរបស់លោក **នួន ជា** នោះដែរ លើកលែងតែការបម្លាស់ទី ប៉ុន្តែវាបានព្យាបាលរួចហើយ។ **ទីបី** បញ្ហាសមត្ថភាពបម្លាស់ទី អាចជះឥទ្ធិពលដល់សមត្ថភាពរបស់ជនជាប់ចោទក្នុងការអង្គុយមិនបានយូរ និងមិនអាចផ្តោតអារម្មណ៍ ប៉ុន្តែលោក **នួន ជា** បានថ្លែងថា គាត់អាចអង្គុយបានរយៈពេល ពីរទៅបីម៉ោង និងអាចផ្តោតអារម្មណ៍រយៈពេលមួយម៉ោងកន្លះ ដែលរយៈពេលនេះសមស្របទៅនឹងរយៈពេលនៃវគ្គសវនាការនីមួយៗនៅក្នុងតុលាការ។

ដើម្បីបង្អាក់ការជឿជាក់នៃការរកឃើញរបស់សាស្ត្រាចារ្យ **ចន ខេមប៊ើល** មេធាវីការពារក្តីរបស់លោក **នួន ជា** បានលើកឡើងនូវតារាងជម្ងឺមួយ ដែលជនជាប់ចោទបានទទួលរងនាពេលកន្លងមក ជាពិសេស ជំងឺដាច់សសៃឈាមក្នុងខួរក្បាលកាលពីឆ្នាំ១៩៩៥។ ទោះបីជាយ៉ាងណា សាស្ត្រាចារ្យ **ចន ខេមប៊ើល** បានពន្យល់តបថា ជំងឺដាច់សរសៃឈាមក្នុងខួរក្បាលដែលលោក **នួន ជា** ទទួលរងកាលពី ១៦ ឆ្នាំមុន គ្រាន់តែជាករណីតូចមួយប៉ុណ្ណោះ ពាក់ព័ន្ធនឹងការស្ទះសរសៃឈាម ដែលមិនអាចបំផ្លាញដល់សមត្ថភាពយល់ដឹងរបស់ជនជាប់ចោទ **នួន ជា** នោះទេ។ ការស្ទះសរសៃឈាមក្នុងខួរក្បាល មិនប៉ះពាល់ដល់មុខងារសាច់ដុំទេ ប៉ុន្តែការផ្លាស់ប្តូរមានកម្រិតតិចតួចបំផុត ហើយពិបាករកឱ្យឃើញពីមូលហេតុជាក់លាក់ណាស់។

មេធាវីការពារក្តីលោក **នួន ជា** ក៏បានលើកឡើងផងដែរនូវក្តីបារម្ភអំពីសម្ពាធឈាមកើនឡើងខ្ពស់របស់កូនក្តីខ្លួន ប៉ុន្តែ សាស្ត្រាចារ្យ **ចន ខេមប៊ើល** បានបញ្ជាក់ថា ក្រុមវេជ្ជសាស្ត្រដែលមើលថែលោក **នួន ជា** បានចាត់ចែងបញ្ហានេះបានសមរម្យណាស់។ ដូចគ្នានេះដែរ លក្ខខណ្ឌបេះដូងរបស់គាត់មានសភាពប្រក្រតីច្រើន ដោយមានការថែទាំព្យាបាលដោយការប្រើថ្នាំ។ លោកសាស្ត្រាចារ្យ បានបង្ហាញថា ការស្ទះសរសៃឈាមបេះដូង មិនមែនជារឿងចម្លែកសម្រាប់មនុស្សមានវ័យដូចលោក **នួន ជា** នោះទេ ប៉ុន្តែគាត់បានទទួលទានថ្នាំសម្រាប់ទប់ស្កាត់ជាបន្តបន្ទាប់។ ទោះបីជា មានការលំបាកខ្លះៗក្នុងការអាន និងការមើលអក្សរ ក៏ជនជាប់ចោទ **នួន ជា** មានសមត្ថភាពក្នុងការយល់ដឹងអំពីឯកសារនានា។ អាស្រ័យហេតុដូចបានលើកឡើង សាស្ត្រាចារ្យ **ចន ខេមប៊ើល** បានសន្និដ្ឋានថា លោក **នួន ជា** អាចយល់ដឹងអំពីដំណើរការនីតិវិធី អាចឆ្លើយនឹងសំណួរ អាចផ្តោតអារម្មណ៍ និងអាចចូលរួមជាមួយអ្នកដទៃបាន។ ហេតុដូចនេះ ជនជាប់ចោទ **នួន ជា** គឺមានកាយសម្បទាសមរម្យអាចចូលរួមសវនាការបាន។

លោក **នួន ជា** បានលើកឡើងពីរដងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង អំពីភាពទន់ខ្សោយនៃស្ថានភាពសុខភាពរបស់គាត់ក្នុងអំឡុងដំណើរការនីតិវិធី។ នៅព្រឹកថ្ងៃដំបូងនៃសវនាការ ជនជាប់ចោទ **នួន ជា** បានអះអាងដោយសម្លេងឮៗ និងច្បាស់ៗថា ទោះបីជាគាត់ចង់ចូលរួមនៅក្នុងដំណើរការនីតិវិធីក៏ដោយ ក៏សុខភាពរបស់គាត់កាន់តែដុនដាប

ទៅៗ ដោយសារវ័យចាស់ជរារបស់គាត់។ គាត់បន្តថា គាត់មានបញ្ហាក្នុងការផ្តោតអារម្មណ៍ ការយល់ដឹង និងការអានឯកសារ។ គាត់បានជម្រាបជូនអង្គជំនុំជម្រះសាលាដំបូងថា គាត់មិនអាចអង្គុយបានយូរទេ ដោយសារតែអាចប៉ះពាល់ដល់កែវភ្នែក ក្បាលរបស់គាត់ឡើងធ្ងន់ និងឈឺខ្នង។ គាត់ក៏បានបញ្ជាក់ដែរថា ការចូលរួមពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍ពីបន្ទប់រង់ចាំ មិនអាចជួយសម្រាលដល់ការលំបាករបស់គាត់ក្នុងការផ្តោតអារម្មណ៍នោះទេ ទោះបីជាមានការបំពាក់បរិក្ខារបច្ចេកទេស និងការយកចិត្តទុកដាក់ពីបុគ្គលិកពេទ្យក៏ដោយ។ គាត់ក៏បានរិះគន់សាស្ត្រាចារ្យ **ចន ខេមប៊េល** ដែលការវាយតម្លៃរបស់គាត់មិនអាចរកឃើញពីភាពអសមត្ថភាពក្នុងការផ្តោតអារម្មណ៍របស់គាត់។ គាត់បានស្នើសុំឲ្យមានការតែងតាំងវេជ្ជបណ្ឌិតថ្មី ដើម្បីពិនិត្យពីបញ្ហាសុខភាពរបស់គាត់ បន្ទាប់មក គាត់សុំចាកចេញពីបន្ទប់សវនាការនៅថ្ងៃនោះ ដោយស្នើសុំចូលរួមពីចម្ងាយពីបន្ទប់សោតទស្សន៍វិញ។ នៅចុងបញ្ចប់នៃសវនាការថ្ងៃទីពីរ ជនជាប់ចោទ **នួន ជា** បានឡើងថ្លែងសារជាថ្មី បន្ទាប់ពីសាស្ត្រាចារ្យ **ចន ខេមប៊េល** បញ្ចប់ការធ្វើសេចក្តីសន្និដ្ឋានអំពីការរកឃើញរបស់លោក។ គាត់បានទទូចថា សុខភាពរបស់គាត់មិននៅដដែលនោះទេ ហើយកាន់តែដុនដាបទៅៗជារៀងរាល់ថ្ងៃ ទាំងផ្លូវកាយ ផ្លូវអារម្មណ៍ និងផ្លូវបញ្ញា។ ផ្ទុយទៅវិញ ដោយផ្អែកលើបញ្ហានេះ សហព្រះរាជអាជ្ញា បានលើកឡើងថា ការពិតទៅ លោក **នួន ជា** មានសមត្ថភាពគ្រប់គ្រាន់ក្នុងការការពារខ្លួន និងអាចចូលរួមក្នុងការជំនុំជម្រះប្រកបដោយប្រសិទ្ធភាព។

### ឃ. សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានជីវភាពឯកជន ផ្ទុយទៅវិញ សិទ្ធិរបស់សាធារណជនក្នុងការទទួលបានព័ត៌មាន

នៅក្នុងសវនាការវគ្គដំបូង ក្រុមមេធាវីការពារក្តីរបស់លោក **នួន ជា** បានលើកឡើងពីសិទ្ធិទទួលបានជីវភាពឯកជន និងស្នើសុំឲ្យមានការបើកសវនាការជាអសាធារណៈ។ មេធាវីការពារក្តីបានលើកឡើងថា ភាគីអាចពិភាក្សាបញ្ហាបានដោយសេរី និងអាចបង្ហាញឯកសារសម្ងាត់នានានៅក្នុងសវនាការអសាធារណៈ។ សហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានជំទាស់នឹងសំណើនេះ។ សហព្រះរាជអាជ្ញាអន្តរជាតិ **អាប់ឌុលហាក់** បានសង្កត់ធ្ងន់ថា ចំណុចសំខាន់ៗនៃការវាយតម្លៃលើលោក **នួន ជា** ត្រូវបានពិភាក្សាជាសាធារណៈរួចហើយ។ ចំណែកឯ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី **អេលីហ្សាប៊ែត ស៊ីម៉ូណូហ្វត** បានបន្ថែមថា ចំណុចជាច្រើននៅក្នុងបញ្ហានេះជារឿងសំខាន់ ហើយវាជាការចាំបាច់ណាស់ដែលសាធារណជនត្រូវយល់ដឹងអំពីអ្វីដែលកើតឡើង និងយល់ដឹងអំពីហេតុផលដែលអង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការសម្រេចចិត្ត។

បន្តិចក្រោយមក អង្គជំនុំជម្រះសាលាដំបូង បានសម្រេចច្រានចោលពាក្យសុំរបស់មេធាវីការពារក្តីលោក **នួន ជា** ក្នុងការស្នើសុំឲ្យមានសវនាការជាអសាធារណៈ និងសម្រេចឲ្យបន្តសវនាការជាសាធារណៈតាមធម្មតា។ អង្គជំនុំជម្រះសាលាដំបូង បានលើកទឡ្ហីករណ៍ថា ចំណុចភាគច្រើននៅក្នុងបញ្ហានេះត្រូវបានធ្វើជាសាធារណៈរួចហើយ តែទោះជាយ៉ាងណា ចៅក្រមបានធានាអះអាងចំពោះជនជាប់ចោទថា ប្រសិនបើចាំបាច់ សវនាការនឹងត្រូវធ្វើជាសម្ងាត់។

### ង. ការបោះបង់សិទ្ធិមិនបង្ហាញខ្លួននៅក្នុងបន្ទប់សវនាការ

ទោះបីជាជនជាប់ចោទអាចលះបង់សិទ្ធិក្នុងការចូលរួមក្នុងដំណើរការនីតិវិធីក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យវេជ្ជបណ្ឌិតរបស់ **អ.វ.ត.ក** ពិនិត្យ និងបញ្ជូនរបាយការណ៍អំពីស្ថានភាពសុខភាព នៅពេលណាដែលជនជាប់ចោទស្នើសុំចូលរួមពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍ពីបន្ទប់រងចាំ ឬទៅបន្ទប់ឃុំឃាំងវិញ។ ការធ្វើបែបនេះ អាចឱ្យអង្គជំនុំជម្រះមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការសម្រេចទៅលើសំណូមពរ។

នាព្រឹកថ្ងៃដំបូង ជនជាប់ចោទ **នួន ជា** បានថ្លែងទៅកាន់អង្គជំនុំជម្រះ ដោយបានប្រកាសថា ទោះបីជាគាត់មានបំណងចូលរួមក្នុងដំណើរការនីតិវិធីនេះក៏ដោយ ក៏មានបញ្ហាលំបាកក្នុងការចូលរួមដែរ ដោយសារតែបញ្ហាសុខភាពរបស់គាត់។ គាត់បានស្នើសុំអង្គជំនុំជម្រះសាលាដំបូង តែងតាំងវេជ្ជបណ្ឌិតម្នាក់ទៀត ដើម្បីពិនិត្យពីស្ថានភាពរបស់គាត់ក្នុងការផ្តោតអារម្មណ៍ ហើយក៏សុំចាកចេញទៅតាមដានពីបន្ទប់រងចាំវិញ។ វេជ្ជបណ្ឌិតបានរាយការណ៍ថា លទ្ធផលនៃការពិនិត្យលោក **នួន ជា** គឺស្ថិតនៅក្នុងកម្រិតធម្មតា។ យោងតាមរបាយការណ៍នេះ អង្គជំនុំជម្រះយល់ឃើញថា មិនមានហេតុផលណាមួយក្នុងការអនុញ្ញាតឱ្យជនជាប់ចោទ **នួន ជា** ត្រឡប់ទៅមន្ទីរឃុំឃាំងនោះឡើយ តែបានអនុញ្ញាតឱ្យគាត់អាចទៅតាមដានពីបន្ទប់រងចាំ ដែលមានបំពាក់ឧបករណ៍សោតទស្សន៍ និងបង្គាប់ឱ្យសន្តិសុខមន្ទីរឃុំឃាំងជូនគាត់ទៅតាមដានពីទីនោះវិញ។

ដោយសារតែវ័យចាស់ជរា និងសុខភាពរបស់ជនជាប់ចោទទាំងបួនរូប យើងអាចប្រមើលឃើញថា បញ្ហាទាក់ទងនឹងសិទ្ធិចូលរួមសវនាការ និងការលះបង់សិទ្ធិមិនចូលរួមសវនាការ នឹងចោទឡើងជាបន្តបន្ទាប់ទៀត។

## III. **ការគ្រប់គ្រងដំណើរការជំនុំជម្រះ**

ក្នុងសវនាការពេញទាំងបីថ្ងៃនេះ យើងឃើញថា អង្គជំនុំជម្រះសាលាដំបូងបានខំប្រឹងប្រែងយ៉ាងគួរឱ្យកត់សម្គាល់ក្នុងការជំរុញដំណើរការនីតិវិធីប្រព្រឹត្តទៅយ៉ាងមានប្រសិទ្ធភាព និងកាន់តែឆាប់រហ័ស។ អង្គជំនុំជម្រះមិនត្រឹមតែចំណាយពេលឆ្លើយតបនូវចំណោទនានារបស់ភាគីទេ អង្គជំនុំជម្រះក៏បានគ្រប់គ្រងដំណើរការនីតិវិធីបានយ៉ាងល្អ ដោយបានណែនាំភាគីឱ្យចៀសវាងការសួរសំណួរច្រំដែល និងសំណួរដែលហួសពីដែនកំណត់ ព្រមទាំងសំណើនានាឱ្យបានសមស្របតាមរបៀបវារៈដែលអង្គជំនុំជម្រះសាលាដំបូងបានកំណត់។ លើសពីនេះទៀត បន្ទាប់ពីការជំទាស់របស់សហព្រះរាជអាជ្ញា **អាប់ឌុលហាក់** អង្គជំនុំជម្រះបានណែនាំមេធាវី **ស៊ុន អារុណ** ឱ្យដាក់បង្ហាញឯកសារដែលគាត់យោងនៅក្នុងទឡ្ហីករណ៍របស់ខ្លួន ដើម្បីឱ្យភាគីអាចយល់ដឹងបាន។

### ក. បញ្ហានៃការបកប្រែភាសា

ការបកប្រែ គឺបានដំណើរការយ៉ាងរលូនក្នុងអំឡុងពេលដំណើរការនេះ សាស្ត្រាចារ្យ **ចន ខេមប៊េល** បានឱ្យដឹងថា ការបកប្រែមានភាពល្អប្រសើរ ទោះបីជាពេលខ្លះឮសូរសម្លេងរំខានពីបន្ទប់បកប្រែ ជាពិសេស ការបកប្រែពីភាសាបារាំងទៅភាសាអង់គ្លេស។ បន្ថែមលើនេះ ភាគីនីមួយៗបានយល់ដឹងពីតម្រូវការនៃការបកប្រែ ដោយបាននិយាយយឺតៗ ដើម្បីឱ្យ

អ្នកបកប្រែអាចតាមទាន់។

**ខ. ការចូលរួមពីសាធារណជន**

មានការចូលរួមយ៉ាងច្រើនពីសំណាក់សាធារណជន ជាពិសេសនៅថ្ងៃទីមួយ និងមានការថយចុះបន្តិចនៅថ្ងៃទីពីរ និងទីបី។

**គ. បញ្ហាបច្ចេកទេស**

មានការដាច់ចរន្តអគ្គីសនី កំឡុងពេលដំណើរការនីតិវិធី។ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូង នៅតែបន្តសវនាការដោយប្រើម៉ាស៊ីនភ្លើង ពេលនោះសាធារណជនមិនអាចស្តាប់ឮការសួរដេញដោលពីបន្ទប់សវនាការទេ ហើយការរងចាំឲ្យប្រព័ន្ធសម្លេងដំណើរការឡើងវិញដូចប្រក្រតី ត្រូវចំណាយពេលមួយសន្ទុះធំ។

**ឃ. ការគ្រប់គ្រងពេលវេលា**

| កាលបរិច្ឆេទ | ចាប់ផ្តើម | សម្រាកពេលព្រឹក | សម្រាក អាហារថ្ងៃត្រង់ | សម្រាក ពេលរសៀល | បិទសវនាការ | ចំនួនម៉ោងសរុប |
|---|---|---|---|---|---|---|
| ថ្ងៃច័ន្ទ 29/08/11 | 09.00 | 10.41 - 11.07 | 12.12 - 13.40 | 15.06 - 15.27 | 16.12 | 4 ម៉ោង និង 57 នាទី |
| ថ្ងៃអង្គារ 30/08/11 | 09.00 | 10.33 - 10.57 | 12.00 - 13.31 | 15.19 - 15.33 | 16.15 | 5 ម៉ោង និង 6 នាទី |
| ថ្ងៃពុធ 31/08/11 | 09.05 | 10.33 - 10.59 | 12.05 - 13.41 | 14.43 - 15.03 | 15.38 | 4 ម៉ោង និង 11 នាទី |

ចំនួនម៉ោងជាមធ្យមក្នុងសវនាការមួយថ្ងៃ ៖ ៤ ម៉ោង ៤៥ នាទី

ចំនួនម៉ោងសរុបក្នុងសប្តាហ៍ ៖ ១៤ ម៉ោង ១៤ នាទី

ចំនួនម៉ោង ថ្ងៃ សប្តាហ៍ សរុប នៅពេលជំនុំជម្រះក្តី ៖ ១៤ ម៉ោង ១៤ នាទី

**អំពីកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម** ៖ ជាកម្មវិធីរបស់គម្រោងផ្តួចផ្តើមយុត្តិធម៌ប្រចាំអាស៊ី-អន្តរជាតិ (Asian International Justice Initiative) ដែលជាកិច្ចសហការរវាង U.C. Berkeley War Crime Study Center និង East-West Center ។ កម្មវិធីនេះ ចេញផ្សាយរបាយការណ៍ប្រចាំសប្តាហ៍ ***អំពីដំណើរការនីតិវិធីសវនាការ*** នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ឬហៅកាត់ថា តុលាការកាត់ទោសខ្មែរក្រហម។ បច្ចុប្បន្ន កម្មវិធីនេះកំពុងដំណើរការឃ្លាំមើលសវនាការកាត់ទោសលើសំណុំរឿងក្តីលេខ ០០២ ប្រឆាំងជនជាប់ចោទចំនួន បួនរូប ៖ លោក នួន ជា លោក អៀង សារី លោក ខៀវ សំផន និងលោកស្រី អៀង ធីរិទ្ធ ។

រាយការណ៍សរសេរដោយក្រុមអ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម ដែលមានសមាសភាពមកពីប្រទេស ៖ កម្ពុជា ហ្វីលីពីន ស្វីស ថៃ និង សហរដ្ឋអាមេរិក។

លោក-អ្នកអាចស្វែងរករបាយការណ៍នេះបានជាភាសា ខ្មែរ និង អង់គ្លេស តាមរយៈ http://krtmonitor.org/ និង http://socrates.berkeley.edu/~warcrime/ ។

EAST-WEST CENTER — AIJI TRIAL MONITORING — WCSC WAR CRIMES STUDIES CENTER UNIVERSITY OF CALIFORNIA, BERKELEY

---

[i] The Trial Chamber appointed Professor A. John Campbell as a medical expert in an Expertise Order dated 4 April 2011 (Confidential)

[ii] *See* Trial Chamber. "Scheduling Order for Preliminary Hearing on the Fitness to Stand Trial" (11 August 2011). E110. The Trial Chamber did not conduct a hearing on Professor Campbell's report on his findings on Ieng Sary's health, as the latter did not challenge the report's conclusion that he was fit to stand trial.

[iii] Trial Chamber, "Transcript of Preliminary Hearing on Fitness to Stand Trial" (29 August 2011). E1/8.1. Lines 15-16. 17.

[iv] *Prosecutor v. Pavle Strugar,* IT-01-42-T. International Criminal Tribunal for the Former Yugoslavia Trial Chamber. "Decision Re The Defense Motion to Terminate Proceedings" (26 May 2004). The Ieng Thirith Defense referred to this case in Document E62/2 (Confidential) and in the Trial Chamber's Expertise Order E62/3 (see footnote 1).